

# សៀវភៅណែនាំស្តីពីការវិភាគការផាត់ចេញពីសង្គមនិងយេនឌ័រ (SEGA)

វឌ្ឍនភាពអាចកើតមាន
លុះត្រាតែយើងធ្វើការរួមគ្នា

ខែតុលា ឆ្នាំ២០១៩

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)

# មាតិកា


បញ្ជីពាក្យកាត់ ..... ២

សេចក្តីផ្តើម ..... ៣

ផ្នែក កៈ និយមន័យវាក្យសព្ទ ..... ៤

ផ្នែក ខៈ ចរិតលក្ខណៈនៃ SEGA ..... ៥

**ជំហានទី ១ៈ ការរៀបចំ** ..... ៥

អនុជំហានទី ១ៈ បង្កើតលក្ខខណ្ឌយោង ..... ៥

អនុជំហានទី ២ៈ បង្កើតក្រុម SEGA ..... ៦

អនុជំហានទី ៣ៈ ត្រួតពិនិត្យមើលឯកសារ ..... ៦

អនុជំហានទី ៤ៈ រៀបចំថវិកា និងផែនការសកម្មភាព ..... ៧

**ជំហានទី ២ៈ សកម្មភាពមុនប្រមូលទិន្នន័យ** ..... ៨

**ជំហានទី ៣ៈ ការប្រមូលទិន្នន័យ** ..... ៨

**ជំហានទី ៤ៈ ការវិភាគទិន្នន័យ** ..... ១០

អនុជំហានទី ១ៈ ការដាក់កូដទិន្នន័យ ..... ១០

អនុជំហានទី ២ៈ ការបកស្រាយទិន្នន័យ ..... ១០

**ជំហានទី ៥ៈ ការសរសេររបាយការណ៍** ..... ១០

**ជំហានទី ៦ៈ សិក្ខាសាលាផ្សព្វផ្សាយ** ..... ១២

ផ្នែក គៈ សេចក្តីសន្និដ្ឋាន ..... ១៣

**ឧបសម្ព័ន្ធ Iៈ គំរូលក្ខខណ្ឌយោង (ToR)** ..... ១៤

**ឧបសម្ព័ន្ធ IIៈ គំរូកម្រងសំណួរ** ..... ១៥

# បញ្ជីពាក្យកាត់

| | |
|---|---|
| AOP | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| CDP | ភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព |
| CDPF | មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព |
| DoE | ការិយាល័យអប់រំស្រុក |
| DoP | នាយកដ្ឋានផែនការ |
| DGPP | អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| FGD | កិច្ចពិភាក្សាក្រុមគោលដៅ |
| KII | ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| PoE | មន្ទីរអប់រំខេត្ត |
| SEGA | ការវិភាគការផាត់ចេញពីសង្គមនិងយេនឌ័រ |
| SEM | គម្រោងពង្រឹងការគ្រប់គ្រងវិស័យអប់រំ |
| SSC | គណៈកម្មការទ្រទ្រង់សាលា |

# សេចក្តីផ្តើម

វិស័យអប់រំ នៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមឡើងវិញពីចំណុចសូន្យ បន្ទាប់ពីវិស័យនេះត្រូវបានបំផ្លិចបំផ្លាញគ្មានសេសសល់ នៅក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតពីពាក់កណ្តាលរហូតដល់ចុងទសវត្សរ៍ឆ្នាំ ១៩៧០។ ចាប់តាំងពីពេលនោះមក ការទទួលបានការអប់រំគឺមានភាពប្រសើរឡើងជាលំដាប់តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីបន្តកិច្ចការពង្រឹងគុណភាពវិស័យអប់រំ ក្រសួងអប់រំយុវជន និងកីឡាបានចាប់ផ្តើមប្រតិបត្តិលើការបង្កើនចំនួនគ្រូបង្រៀននិងធ្វើកំណែទម្រង់ការគ្រប់គ្រងនៅតាមសាលារៀនដោយមានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍នានា។

ទោះបីជាមានការធ្វើកំណែទម្រង់ និងមានភាពប្រសើរជារួមនៅក្នុងប្រព័ន្ធវិស័យអបរំក៏ដោយ ក៏កុមារមួយចំនួននៅតែត្រូវបានរារាំងពីការទទួលបានការអប់រំប្រកបដោយគុណភាព ឬពីការសិក្សាដ៏ល្អប្រសើរ និងឱកាសរៀនរហូតដល់បញ្ចប់ការសិក្សាទោះបីជាពួកគេទទួលបានការអប់រំនេះក៏ដោយ។ ជួនកាលដោយសារតែកុមារមានតម្រូវការរៀនសូត្រដែលគ្រូបង្រៀន ឬនាយកសាលាមិនបានដឹង ឬមិនអាចបំពេញតាមតម្រូវការទាំងអស់នោះដោយសារតែពុំមានជំនួយ។ ក្នុងករណីខ្លះទៀត កុមារបោះបង់ការសិក្សា ពីព្រោះពួកគេលែងត្រូវបានរំពឹងឱ្យបន្តការសិក្សាតទៅទៀត។ ការរំពឹងទុកទាំងនេះជារឿយៗបានចាក់ឫសគល់នៅក្នុងបទដ្ឋានយេនឌ័រឧទាហរណ៍របៀបដែលសង្គមមើលឃើញចំពោះតួនាទីរបស់ក្មេងប្រុស និងក្មេងស្រី បុរសនិងស្ត្រី។ ហើយកុមារមួយចំនួនមិនចូលសាលារៀន ពីព្រោះសម្រាប់ពួកគេ សាលារៀនមិនមែនជាកន្លែងដែលមានសុវត្ថិភាព និងមានផាសុកភាពដូចជាអ្វីដែលយើងគិតនោះឡើយ។ ទោះបីដោយសារហេតុផលអ្វីក៏ដោយ នៅថ្នាក់ណាក៏ដោយ នៅពេលដែលកុមារត្រូវបានរារាំងពីការទទួលបានការរៀនសូត្រល្អប្រសើរ និងការបញ្ចប់ការសិក្សាដោយជោគជ័យ យើងអាចនិយាយបានថាជាការផាត់ចេញពីសង្គម។

ជំហានដំបូងដើម្បីធានាថា កុមារគ្រប់រូប អាចរៀនសូត្របានល្អប្រសើរនិងជោគជ័យនៅក្នុងសាលារៀនគឺត្រូវធ្វើការស្វែងយល់ឱ្យបានស៊ីជម្រៅថាតើកុមាររូបណាខ្លះមិនត្រូវបានគេគិតគូរ និងមូលហេតុរបស់វា។ នេះគឺជាសនិទាននៃការវិភាគការផាត់ចេញពីសង្គមនិងយេនឌ័រ (SEGA)។ SEGA នឹងផ្តល់ព័ត៌មានដែលត្រូវការជាចាំបាច់សម្រាប់ការផ្តល់នូវការអប់រំប្រកបដោយសមធម៌និងបរិយាបន្ន ឧទាហរណ៍ ការអប់រំដែលស័ក្តិសមសម្រាប់មនុស្សរាល់គ្នា។ ដូចនេះ បុគ្គលដែលទទួលខុសត្រូវក្នុងការធ្វើផែនការនិងផ្តល់ការអប់រំគឺត្រូវបានលើកទឹកចិត្តឱ្យបន្តអនុវត្ត SEGA ជាប្រចាំ។ ឯកសារ SEGA នេះជួយបំពាក់បំប៉នពួកគេនូវជំនាញចាំបាច់ក្នុងការទាញយកព័ត៌មានស៊ីជម្រៅចាប់ពីថ្នាក់សិក្សាដំបូងបង្អស់ជាពិសេសកុមារនិងយុវជនដែលកំពុងសិក្សានិងបោះបង់ការសិក្សា កុមារានិងកុមារី ដែលមានឬមិនមានពិការភាព ឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេ គ្រូបង្រៀន និងនាយកសាលាដើម្បីផ្តល់ឯកសារដោយផ្អែកលើភស្តុតាងសម្រាប់ការបង្កើតផែនការវិស័យអប់រំនៅថ្នាក់ខេត្តស្រុកនិងសាលារៀន។ ស្របពេលជាមួយគ្នានេះដែរ SEGA ក៏ជួយធ្វើឱ្យអ្នកបង្កើតគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តយល់ដឹងអំពីការផាត់ចេញពីសង្គមនិងបញ្ហាយេនឌ័រ ហើយឯកសារនេះផ្តល់នូវភស្តុតាងសម្រាប់ការធ្វើវិភាជន៍ធនធានដែលមានស្រាប់ទៅកាន់កន្លែងដែលត្រូវការចាំបាច់ជាងគេបំផុត។

សៀវភៅណែនាំស្តីពី SEGA នេះត្រូវបានចងក្រងឡើងដើម្បីសម្រួលដល់ការសិក្សាអំពីវិសមភាពយេនឌ័រ និងការផាត់ចេញពីសង្គមសង្គម។ បន្ថែមពីលើនេះទៅទៀត សៀវភៅណែនាំនេះគឺត្រូវបានបងកើតឡើងដើម្បីធ្វើជាឧបករណ៍មួយក្នុងការកំណត់រកក្រុមប្រជាជន និងកុមារងាយរងគ្រោះ និងក្រុមប្រជាជនដែលមិនបានផាត់ចេញពីអនុវត្តសិទ្ធិមូលដ្ឋានរបស់ពួកគេក្នុងការទទួលបានការអប់រំ ព្រមទាំងដើម្បីមានឥទ្ធិពលដល់ការបង្កើតគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។

សរុបមក សៀវភៅណែនាំស្តីពី SEGA មានគោលដៅគាំទ្រដល់បុគ្គលដែលទទួលខុសត្រូវក្នុងការសម្របសម្រួលធ្វើផែនការនិងផ្តល់ការអប់រំ ឱ្យយល់ដឹងអំពីអ្នកដែលត្រូវបានរារាំងក្នុងការសិក្សាល្អប្រសើរនិងការបញ្ចប់ការសិក្សាប្រកបដោយជោគជ័យក៏ដូចជាហេតុផលនៃការផាត់ចេញពីសង្គម។ សៀវភៅណែនាំនេះក៏គាំទ្រដល់ពួកគាត់ក្នុងការប្រមូលភស្តុតាងដើម្បីអនុវត្តន៍វិធានការឆ្ពោះទៅសម្រេចឱ្យបាន ប្រកបដោយជោគជ័យនូវគោលដៅដែលធានាថាគ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ។

# ផ្នែក ក៖ និយមន័យវាក្យសព្ទ

**តើពាក្យ SEGA មានន័យដូចម្តេច ?**

**SEGA** មានន័យថា ការវិភាគការផាត់ចេញពីសង្គមនិងយេនឌ័រ។

***ការផាត់ចេញពីសង្គម***សំដៅដល់ប្រជាជនឬក្រុមប្រជាជនដែលត្រូវបានគេបដិសេធជាលក្ខណៈប្រព័ន្ធចំពោះសិទ្ធិធនធានសេវាកម្ម ឱកាស សេចក្តីថ្លៃថ្នូរ និងសមត្ថភាពក្នុងការចូលរួមក្នុងជីវិតសង្គមសេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។

***សមភាពយេនឌ័រ*** ជាស្ថានភាពមួយដែលស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស និងបុគ្គលដែលមិនត្រូវបានកំណត់ថាជាបុរស ឬស្រី និងដែលអាចទទួលបានសិទ្ធិ ធនធាន ឱកាស និងការការពារដូចគ្នា។



# ផ្នែក ខ៖ ចរិតលក្ខណៈនៃ SEGA

ដំណើរការរបស់ SEGA ផ្តល់នូវទស្សនាទានសំខាន់សម្រាប់វិសមភាពយេនឌ័រ និងការផាត់ចេញពីសង្គមហើយឧបករណ៍នេះជួយដល់អ្នកធ្វើផែនការវិស័យអប់រំក្នុងការសម្រេចចិត្តថាតើត្រូវសួរអ្វីសួរនរណាហើយត្រូវសួររបៀបណាដើម្បីទាញយកព័ត៌មានស៊ីជម្រៅសម្រាប់ធ្វើការវិភាគ។ លើសពីនេះទៅទៀតឯកសារនេះជួយឱ្យអ្នកធ្វើផែនការយុទ្ធសាស្ត្រវិស័យអប់រំរួមទាំងនាយកសាលាសម្លឹងមើលកាន់តែទូលំទូលាយចំពោះបញ្ហាការផាត់ចេញពីសង្គម និងវិសមភាពយេនឌ័រនៅក្នុងបរិបទនេះ។

SEGA គឺជាដំណើរការស្រាវជ្រាវបែបគុណវិស័យ ដោយចាប់ផ្តើមពីការស្រាវជ្រាវទិន្នន័យពីប្រភពទីពីរ ដូចជា EMIS របាយការណ៍សមិទ្ធកម្មថ្នាក់ស្រុក និងខេត្ត ការសិក្សា និងការវាយតម្លៃគម្រោងដែលបានធ្វើឡើងដោយ អង្គការមិនមែនរដ្ឋាភិបាល។ ការស្រាវជ្រាវនេះគឺធ្វើឡើងតាមរយៈកិច្ចពិភាក្សាក្រុមគោលដៅ (FGDs) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) ដើម្បីប្រមូលព័ត៌មានអំពីចំណេះដឹង ឥរិយាបទ ការអនុវត្ត និងគោលគំនិតរបស់អ្នកប្រើប្រាស់សេវាកម្ម និងអ្នកផ្តល់សេវាកម្ម។អ្នកប្រើប្រាស់សេវាកម្មអាចរួមមាន កុមារ និងយុវជនដែលកំពុងសិក្សា និងដែលមិនបានចូលសិក្សា កុមារា និងកុមារីដែលមាន ឬមិនមានពិការភាព ឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេ ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលាផងដែរ។អ្នកផ្តល់សេវាកម្មអាចរួមមានគ្រូបង្រៀន និងនាយកសាលា។

កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) គឺជាកិច្ចសន្ទនាធ្វើឡើងតាមការណែនាំដែលមានរយៈពេលមួយម៉ោងជាមួយ នឹងអ្នកប្រើប្រាស់សេវាកម្ម និងអ្នកផ្តល់សេវាកម្មដែលធ្វើឡើងជាក្រុមពី ៣ ទៅ ៥ នាក់។ កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) គួររួមបញ្ចូលក្មេងប្រុស និងក្មេងស្រី បុរស និងស្ត្រីដែលមានអាយុខុសៗគ្នា។ អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សានេះត្រូវមានសមភាពយេនឌ័រ ហើយយល់ល្អ កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) នេះត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នាទៅតាមប្រភេទយេនឌ័រនីមួយៗដើម្បីធានាថាអ្នកចូលរួមទាំងនោះមានអារម្មណ៍ងាយស្រួលក្នុងការនិយាយ។

ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) គឺជាកិច្ចសម្ភាសន៍ដែលគ្មានរចនាសម្ព័ន្ធ និងសម្ភាសន៍ម្តងម្នាក់ៗជាមួយនឹងអ្នកប្រើប្រាស់សេវាកម្មនិងអ្នកផ្តល់សេវាកម្ម។ជាធម្មតាកិច្ចសម្ភាសន៍នេះមានរយៈពេលយ៉ាងយូរបំផុតមួយម៉ោង។

កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) គឺអាស្រ័យទៅលើកម្រងសំណួរ (សំណួរតម្រង់ទិស)។ ឯកសារស្រាវជ្រាវទាំងនេះរួមមានកម្រងសំណួរដែលប្រើប្រាស់ក្នុងគោលបំណងប្រមូលព័ត៌មានពីអ្នកឆ្លើយ។ ការស្រាវជ្រាវ SEGA ជាការស្រាវជ្រាវបែបគុណវិស័យដែលតម្រូវឱ្យប្រើប្រាស់សំណួរបើក។ សំណួរបើកគឺជាសំណួរដែលតម្រូវឱ្យឆ្លើយលើសពីមួយពាក្យ។ចម្លើយត្រូវតែមានទម្រង់ជាបញ្ជីពីរបីប្រយោគ ឬជាកថាខ័ណ្ឌ។

ទំហំសំណាករបស់ SEGA គឺអាស្រ័យទៅលើវិសាលភាពក្របខ័ណ្ឌពេលវេលានិងអត្ថិភាពនៃថវិកានិងមនុស្សដែលយើងចង់បានសម្រាប់អនុវត្ត SEGA នោះ។

ពេលវេលាដ៏ល្អប្រសើរសម្រាប់ធ្វើ SEGA គឺមុនពេលធ្វើផែនការ និងបែងចែកធនធាន គួរតែបង្កើត ដំណើរការពិគ្រោះយោបល់មួយដើម្បីអាចយកលទ្ធផលរកឃើញនៃ SEGA ទៅប្រើប្រាស់ និងដាក់បញ្ចូលក្នុងផែនការ និងថវិកាទាំងនេះបាន។

ដើម្បីធ្វើSEGAមានជំហានចំនួន៦ដែលត្រូវអនុវត្តដូចមានរៀបរាប់ខាងក្រោម៖

## ជំហានទី ១៖ ការរៀបចំ

**នៅក្នុងជំហានទី១ មានអនុជំហានចំនួន៤៖**

❖ **អនុជំហានទី ១៖ ទម្រង់ការងារនៃរយៈពេលយោង (ToR)**

ជំហាននេះផ្តោតសំខាន់ ទៅលើផែនការរបស់អ្នកស្រាវជ្រាវសម្រាប់ការសិក្សា។ ផែនការនេះផ្តល់នូវគោលបំណងនៃការស្រាវជ្រាវ ការកំណត់បញ្ហា វិធីសាស្ត្រស្រាវជ្រាវ វិសាលភាពនៃការសិក្សា ទំហំគំរូ ពេលវេលា និងលទ្ធផលរំពឹងទុក។ ផែនការស្រាវជ្រាវ SEGA មានកំណត់នៅក្នុងឯកសារ ទម្រង់ការងារនៃរយៈពេលយោង (ToR))។ សូមមើលឧបសម្ព័ន្ធ ១ សម្រាប់ទម្រង់គំរូ។

- ***សាវតារបរិបទ៖*** ផ្នែកនេះគឺមានចែងអំពីសាវតារនៃការស្រាវជ្រាវ និងផ្តល់នូវកត្តាមូលដ្ឋានដែលមានឥទ្ធិពលដល់វិស័យអប់រំ (ស្ថានភាពប្រជាសាស្ត្រ ភូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធលក្ខខណ្ឌ រស់នៅក្នុងមូលដ្ឋាន អត្រាភាពក្រីក្រ ភាសាក្នុងស្រុក -ល-)។
- **លំនាំបញ្ហា៖** ជាសេចក្តីពណ៌នាសង្ខេបអំពីបញ្ហាដែលនឹងត្រូវដោះស្រាយ ឬស្ថានភាពដែលត្រូវកែលម្អ។ សេចក្តី

ថ្លែងបញ្ហាត្រូវតែរៀបរាប់លម្អិតអំពីបញ្ហាជាក់លាក់ ហើយការស្រាវជ្រាវមានគោលដៅក្នុងការឆ្លើយតបទៅនឹងបញ្ហា ឬគោលបំណងនៃការស្រាវជ្រាវ។ ជារួមត្រូវមានភាពច្បាស់លាស់ ត្រឹមត្រូវ ពិតប្រាកដជាក់ស្តែង និងពាក់ព័ន្ធនឹងបរិបទនៃការស្រាវជ្រាវ។

- **គោលបំណង៖** SEGAមានគោលបំណងរួមដើម្បីស្វែងយល់ និងរកឱ្យឃើញនូវដើមចមដែលជាមូលហេតុធ្វើឱ្យកុមារ និងយុវជនរៀនមិនបានល្អ និងមិនបានជោគជ័យក្នុងការរៀនសូត្រ និងដើម្បីធ្វើការវាយតម្លៃអំពីជំនឿរបស់ពួកគេ និងឪពុកម្តាយ/អ្នកថែទាំរបស់ពួកគេក្នុងការផ្លាស់ប្តូរ/អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពបំផុត។
- **វិធីសាស្ត្រស្រាវជ្រាវ៖** ភាពចម្រុះគ្នានៃកិច្ចពិភាក្សាក្រុមគោលដៅ (FGDs) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII) ត្រូវបានប្រើប្រាស់ដើម្បីទាញយកព័ត៌មានពីអ្នកប្រើប្រាស់សេវាកម្ម និងអ្នកផ្តល់សេវាកម្ម។
- **ទំហំសំណាក៖** អាស្រ័យទៅលើគម្រោងថវិកានិងធនធានមនុស្សដែលមាន។
- **ក្របខ័ណ្ឌពេលវេលា៖** អាស្រ័យទៅលើវិសាលភាព និងទំហំគំរូនៃការស្រាវជ្រាវ។

❖ **អនុជំហានទី ២៖ បង្កើតក្រុម SEGA**

ក្រុមSEGAគួរមានសមាជិកចាប់ពី៣ទៅ៧នាក់។ចំនួនសមាជិកក្រុមត្រូវតែសម្រេចចិត្តទៅតាមវិសាលភាព ថវិកា និងក្របខ័ណ្ឌពេលវេលានៃការស្រាវជ្រាវ។ សម្រាប់ការអនុវត្តជាក់ស្តែង សូមណែនាំឱ្យមានការបង្កើតក្រុម ដោយមានតុល្យភាពយេនឌ័រដែលមានសមាសភាគមកពីស្រុកតែមួយ។ ឧទាហរណ៍ ប្រសិនមន្ត្រីការិយាល័យអប់រំស្រុកនិងនាយកសាលាត្រូវបានជ្រើសរើសធ្វើជាក្រុម SEGA នៅក្នុងស្រុក ម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវតែជាស្ត្រីភេទ។ ក្នុងអំឡុងពេលបង្កើតក្រុម ត្រូវតែពិភាក្សាគ្នាអំពីតួនាទី និងទំនួលខុសត្រូវ និងការចាត់តាំងតួនាទី (តើនរណាជាអ្នកសម្របសម្រួលនិងកត់ត្រា?)។ ប្រធានក្រុមដើរតួនាទីក្នុងការដឹកនាំធ្វើផែនការសម្របសម្រួលសកម្មភាពគាំទ្រលក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេស និងធានាគុណភាពនៃការស្រាវជ្រាវ។

**ត្រូវកំណត់តួនាទីឱ្យបានច្បាស់លាស់ដូចខាងក្រោម៖**

១. ប្រធានក្រុម – ទទួលខុសត្រូវដឹកនាំ ធ្វើផែនការ និងសម្របសម្រួល
២. អ្នកសម្របសម្រួល–សម្របសម្រួលកិច្ចពិភាក្សាក្រុមគោលដៅ (FDG) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII)
៣. អ្នកកត់ត្រា

ការជ្រើសរើសសមាជិកក៏ជាកត្តាដ៏សំខាន់មួយផងដែរក្នុងការធានានូវគុណភាព និងពង្រីកនូវឥទ្ធិពល SEGA ដែលជាលទ្ធផលនៅពេលដែលបុគ្គលម្នាក់ត្រូវបានជ្រើសរើសជាសមាជិកក្រុម SEGA បុគ្គលរូបនោះត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ជាមន្ត្រីរៀបចំផែនការ /ប្រធានមន្ទីរអប់រំខេត្ត/ការិយាល័យអប់រំស្រុក
- ជាជនបង្គោលផ្នែកយេនឌ័រ និងបរិយាបន្នសង្គមនៅមន្ទីរអប់រំខេត្ត/ការិយាល័យអប់រំស្រុក/សាលារៀន
- ជានាយក/នាយិកាសាលាបឋមសិក្សានាយកសាលាកម្រង
- ប្តេជ្ញាចិត្តមោះមុតក្នុងការចូលរួមនិងសិក្សារៀនសូត្រ
- មានពេលវេលាគ្រប់គ្រាន់ក្នុងការប្រជុំ និងធ្វើដំណើរទៅកាន់ទីតាំងផ្ទាល់
- មានឆន្ទៈ ក្នុងការលើកកម្ពស់វិស័យអប់រំប្រកបដោយបរិយាបន្ននៅសាលារៀនក្នុងមូលដ្ឋាន

ប៉ុន្តែ មិនមែនមានន័យថា សមាជិករបស់ SEGA ទាំងអស់ត្រូវតែបំពេញគ្រប់លក្ខខណ្ឌតម្រូវខាងលើទាំងអស់នោះទេ។ ប្រសិនបើបុគ្គលនោះមានលក្ខណៈវិនិច្ឆ័យមួយចំនួនក្នុងចំណោមលក្ខណៈវិនិច្ឆ័យខាងលើនេះបុគ្គលរូបនោះនឹងអាចជួយបង្កើនស្មារតីក្រុម និងចូលរួមយ៉ាងសកម្មផងដែរ។

❖ **អនុជំហានទី៣៖ ត្រួតពិនិត្យមើលឯកសារ**

ការត្រួតពិនិត្យឯកសារ គឺជាការពិនិត្យមើលធនធានដែលមានស្រាប់ ដូចជា ស្ថិតិពាក់ព័ន្ធរបស់ភូមិ ឃុំ EMIS របស់សាលារៀន របាយការណ៍សមិទ្ធផលរបស់ស្រុក ខេត្ត ការសិក្សា និងការវាយតម្លៃគម្រោងនានាដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ឬលទ្ធផលនៃការស្រាវជ្រាវបែប សកម្មភាពប្រសិនបើមាន និងធនធានដែលគួរឱ្យទុកចិត្តផ្សេងៗទៀត។ ធនធានទាំងនេះជួយក្រុមស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ ឬព័ត៌មានសំខាន់ៗចាំបាច់ ដែលពាក់ព័ន្ធនឹងការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រនៅក្នុងវិស័យអប់រំនៅក្នុងបរិបទនៃការស្រាវជ្រាវ។ ដូចនេះ អ្នកស្រាវជ្រាវអាចទទួលបាននូវការយល់ដឹងកាន់តែច្រើនបន្ថែមទៀតអំពីបញ្ហាក៏ដូចជារបៀបស្រាវជ្រាវដែលពួកគេអាចរៀបចំបានតាមរយៈស្ថិតិ និងព័ត៌មានជាក់ស្តែងទាំងនេះ។

ការស្រាវជ្រាវឯកសារនៅពេលធ្វើ SEGA ជួយឱ្យអ្នកស្រាវជ្រាវក្នុងការសម្លឹងមើលពីទីតាំងនៃចំណុចខ្វះចន្លោះនៅក្នុងទិន្នន័យបច្ចុប្បន្ន និងទិន្នន័យដែលពួកគេមានបំណងចង់ស្រាវជ្រាវបន្ថែមទៀត។ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS)គឺជាជំហានដំបូងដ៏សមរម្យបំផុតមួយ។ លើសពីនេះទៅទៀត ប្រព័ន្ធនេះអាចរំឭកអ្នកស្រាវជ្រាវឱ្យពិចារណាលើរបៀបនៃការធ្វើបច្ចុប្បន្នភាព EMIS ជាមួយនឹងតួលេខ ឬភាគរយនៃសិស្សដែលងាយរងគ្រោះ ដូចជា សិស្សក្រីក្រ សិស្សមានពិការ សិស្សជនជាតិដើមភាគតិច និងសិស្សជនជាតិភាគតិច ដើម្បីធានាថាសិស្សគ្រប់រូបគឺត្រូវបានគិតគូរ។

| សេចក្តីពណ៌នា | ចំនួនសរុប % | ស្រី | អត្តសញ្ញាណភេទផ្សេងទៀត | ក្រីក្រ | ពិការ | ជនជាតិភាគតិច | ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជននៅក្នុង ភូមិ/ឃុំ | | | | | | | |
| សិស្សក្នុងសាលារៀន | | | | | | | |
| ការចុះឈ្មោះចូលរៀនរបស់សិស្ស | | | | | | | |
| សិស្សត្រួតថ្នាក់ | | | | | | | |
| សិស្សបោះបង់ការសិក្សា | | | | | | | |
| កុមារ/យុវជននៅក្រៅសាលារៀន | | | | | | | |
| គ្រូបង្រៀន | | | | | | | |
| គណៈកម្មការទ្រទ្រង់សាលា (SSC) | | | | | | | |
| ជនបង្គោលផ្នែក យេនឌ័រក្នុងសាលា | | | | | | | |

បន្ទាប់ពីត្រួតពិនិត្យឯកសារ ក្រុមស្រាវជ្រាវនឹងទទួលបានទិន្នន័យជាក់លាក់ដែលអាចប្រើប្រាស់ដើម្បីធ្វើការចាប់យកគំរូស្រាវជ្រាវដោយចៃដន្យ។ ជាលទ្ធផល ចំនួនសាលារៀនកិច្ចពិភាក្សាក្រុមគោលដៅ (FGDs) ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) អ្នកឆ្លើយតប និងរយៈពេលនៃកិច្ចការស្រាវជ្រាវគឺត្រូវបានកំណត់និងព្រមព្រៀង។

❖ **អនុជំហានទី ៤៖ រៀបចំថវិកា និងផែនការសកម្មភាព**

បន្ទាប់ពីធ្វើការត្រួតពិនិត្យឯកសាររួច ក្រុមអាចចាប់ផ្តើមរៀបចំផែនការសកម្មភាព និង ថវិកាបានហើយ។ នៅក្នុងដំណើរការ SEGA គឺមានដំណាក់កាលសកម្មភាពមួយចំនួនដូចជា ការជួបប្រជុំជាមុន ការចុះប្រមូលទិន្នន័យ ការបញ្ចូលនិងបកស្រាយទិន្នន័យ ការសរសេររបាយការណ៍ និងចុងក្រោយ គឺសិក្ខាសាលា បង្ហាញលទ្ធផលស្រាវជ្រាវ SEGA។ តាមសកម្មភាពនីមួយៗមានតម្រូវការសំភារៈប្រើប្រាស់ និងចំណាយខុសៗគ្នាតាមសកម្មភាពនោះ ដូចជាការទូទាត់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ថ្លៃស្នាក់នៅ ធ្វើដំណើរ អាហារសម្រន់ ក្រដាសធំសម្រាប់សរសេរ ហ្វឺត និងឯកសារបោះពុម្ពផ្សេងៗទៀត -ល-។ វាតម្រូវឱ្យអ្នកស្រាវជ្រាវ ជាពិសេសប្រធានក្រុមត្រូវរៀបចំដោយយកចិត្តទុកដាក់ខ្ពស់ និងបម្រុងថវិកាតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។

តារាងខាងក្រោមបង្ហាញពីឧទាហរណ៍នៃរបៀបគ្រប់គ្រងរៀបចំផែនការថវិកា៖

| ចំនួនសកម្មភាព | សេចក្តីពណ៌នា | ឯកតា | ចំនួនឯកតា | ចំនួនស្រុក | ចំនួនថ្ងៃ/យប់ | ថ្លៃចំណាយ | សរុប | យុត្តិកម្ម |
|---|---|---|---|---|---|---|---|---|
| ១ | **ការប្រជុំជាមុន** | | | | | | | |
| | ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | នាក់ | | | | | | |
| | ស្នាក់នៅ | នាក់ | | | | | | |
| | ធ្វើដំណើរ | នាក់ | | | | | | |
| | អាហារសម្រន់ | នាក់ | | | | | | |
| | ការរៀបចំ/សម្ភារ | ឯកតា | | | | | | |
| | | | | | **សរុបរួម** | | | |

ក្រៅពីផែនការថវិកា ក៏ត្រូវតែបង្កើតផែនការសកម្មភាពផងដែរដើម្បីគាំទ្រការស្រាវជ្រាវ។

ដូចនេះសូមមើលតារាងខាងក្រោមជាឧទាហរណ៍គំរូ៖

| លេខ | សកម្មភាព | ឈ្មោះសាលា / ឈ្មោះទីកន្លែង | ខេត្ត/ស្រុក | ក្រុមគោលដៅ | ចំនួនថ្ងៃ | កាលបរិច្ឆេទចាប់ផ្តើម |
|---|---|---|---|---|---|---|
| ១ | ការប្រជុំជាមុន | | | | | |
| ២ | ការប្រមូល | | | | | |
| ៣ | ការបញ្ចូលទិន្នន័យ | | | | | |
| ៤ | សរសេររបាយការណ៍ | | | | | |
| ៥ | សិក្ខាសាលាធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវ SEGA | | | | | |

តារាងទាំងពីរខាងលើ គឺប្រើប្រាស់សម្រាប់ពណ៌នាលម្អិតអំពីផែនការ។ ស្របពេលជាមួយគ្នានេះដែរ តារាងទាំងពីរនេះក៏ធ្វើឱ្យក្រុមស្រាវជ្រាវមើលឃើញកាន់តែច្បាស់អំពីចំនួនថវិកាដែលត្រូវការ និងរយៈពេលដែលពួកគេត្រូវចាប់ផ្តើមដល់បញ្ចប់ការស្រាវជ្រាវរបស់ពួកគេ។

## ជំហានទី ២៖ សកម្មភាពមុនប្រមូលទិន្នន័យ

មុនពេលចុះទៅប្រមូលទិន្នន័យ ជាការចាំបាច់បំផុតក្នុងការរៀបចំកិច្ចប្រជុំជាមុនក្នុងគោលបំណងពិនិត្យមើលពីផែនការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ បញ្ជាក់អំពីទំនួលខុសត្រូវរបស់ក្រុម និងកំណត់កម្រងសំណួរឱ្យបានត្រឹមត្រូវ។ ប្រធានក្រុមគឺជាអ្នកសម្របសម្រួលចម្បងនៅក្នុងកិច្ចប្រជុំជាមុននេះ ហើយជាធម្មតាកិច្ចប្រជុំនេះគឺត្រូវចំណាយរយៈពេលកន្លះថ្ងៃ។

របៀបវារៈខាងក្រោមនេះបង្ហាញអំពីដំណើរការនេះយ៉ាងលម្អិត៖

| ប្រធានបទ | ពេលវេលាត្រូវការ | អ្នកសម្របសម្រួល |
|---|---|---|
| ការអញ្ជើញមកដល់ និងចុះឈ្មោះអ្នកចូលរួម | ១៥ នាទី | ប្រធានក្រុម |
| ស្វាគមន៍អ្នកចូលរួម និងធ្វើបទបង្ហាញពីកម្មវត្ថុចម្បងនៃកិច្ចប្រជុំ | ១០ នាទី | ប្រធានក្រុម |
| ធ្វើបទបង្ហាញពីផែនការសិក្សាលម្អិតដល់សមាជិកក្រុមទាំងមូលជាមួយនឹងកិច្ចពិភាក្សាអំពីតម្រូវការសំភារៈប្រើប្រាស់ អ្នកទទួលខុសត្រូវប្រមូលទិន្នន័យ និងការបញ្ជាក់ពីរចនាសម្ព័ន្ធក្រុម (តួនាទីអាចផ្លាស់ប្តូរគ្នាបានប្រសិនបើចាំបាច់) | ៣០ នាទី | ប្រធានក្រុម |
| **សម្រាកអាហារសម្រន់** | ១៥ នាទី | ក្រុម SEGA |
| កំណត់កម្រងសំណួរសម្រាប់កិច្ចពិភាក្សាក្រុមគោលដៅ (FGD) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII) ដើម្បីពិនិត្យមើលពីកម្រិតយល់ដឹងរបស់ពួកគេអំពីសំណួរតម្រង់ទិសនីមួយៗ | ១ ម៉ោង | ក្រុម SEGA |
| សម្តែងសកម្មភាព (ក្រុមអនុវត្តការសម្របសម្រួល និងសួរសំណួរតម្រង់ទិស) | ៤៥ នាទី | ក្រុម SEGA |
| បញ្ចប់កិច្ចប្រជុំជាមុន | ៥ នាទី | ក្រុម SEGA |

## ជំហានទី ៣៖ ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យគឺជាដំណើរការនៃការប្រមូលព័ត៌មាន/ទិន្នន័យពីភាគីពាក់ព័ន្ធនិងអ្នកប្រើប្រាស់សេវាកម្មដើម្បីស្វែងរកចម្លើយសម្រាប់លំនាំបញ្ហានៃការស្រាវជ្រាវ។ នៅក្នុងវដ្តនៃកិច្ចការស្រាវជ្រាវការប្រមូលទិន្នន័យក៏ជាជំហានមួយដ៏សំខាន់ផងដែរនៅក្នុងការចម្រាញ់យកព័ត៌មាន/ចម្លើយដែលត្រឹមត្រូវ និងសម្រាប់ធ្វើការវិភាគ។ ហេតុដូចនេះ ការចុះប្រមូលទិន្នន័យគឺត្រូវតែធ្វើផែនការ រៀបចំ និងសម្របសម្រួលឱ្យបានល្អប្រសើរបំផុត។

ជាដំបូង ក្រុមត្រូវតែបែងចែកទៅជា ៣ក្រុមតូចៗដែលក្នុងមួយក្រុមមានគ្នា ២នាក់ (ការិយាល័យអប់រំស្រុកម្នាក់ និងនាយក/នាយិកា

សាលាម្នាក់មកពីស្រុកតែមួយ) ទទួលខុសត្រូវស្រុកមួយ។ ជំហានទីពីរ សមាជិកមន្ទីរអប់រំខេត្ត ដែលជាប្រធានក្រុមស្រាវជ្រាវដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេស ប៉ុន្តែប្រធានក្រុមរូបនេះមិនអាចគាំទ្រក្រុមបីក្នុងពេលតែមួយបានទេ។ ហេតុដូចនេះហើយ ប្រធានក្រុមអាចជ្រើសរើសក្រុមណាមួយក្នុងចំណោមទាំងបីក្រុមនេះដោយផ្អែកលើសមត្ថភាព និងតម្រូវការរបស់ពួកគេដើម្បីធានាគុណភាពនៃការប្រមូលទិន្នន័យ។

ដើម្បីទទួលបានទិន្នន័យសំខាន់ៗ តម្រូវឱ្យអ្នកស្រាវជ្រាវមានជំនាញក្នុងការសម្របសម្រួល និងប្រាស្រ័យទាក់ទងល្អប្រសើរ។ អ្នកស្រាវជ្រាវគួរតែព្យាយាមចៀសវាងមិនប្រើអាកប្បកិរិយាទាំងឡាយណាដែលអាចបង្អាក់អ្នកឆ្លើយតបក្នុងការបញ្ចេញគំនិតយោបល់ពិត ឬបាត់បង់ទំនុកចិត្តមកលើក្រុមស្រាវជ្រាវ។ ជាលទ្ធផល ក្នុងអំឡុងពេលធ្វើសម្ភាសន៍ ឬពិភាក្សាក្រុម ក្រុមស្រាវជ្រាវត្រូវតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌ដូចខាងក្រោម៖

**អ្វីដែលអ្នកស្រាវជ្រាវគួរធ្វើ៖**

- ស្តាប់ និងអង្កេត
- ព្យាយាមយល់ពីអ្នកឆ្លើយតប
- អត់ធ្មត់ និងឱនលំទោន
- លើកទឹកចិត្ត និងជម្រុញទឹកចិត្តអ្នកឆ្លើយតប
- គោរព និងផ្តល់តម្លៃដល់អ្នកចូលរួម
- មានភាពបត់បែន និងច្នៃប្រឌិត
- និយាយច្បាស់ៗ
- ប្រើប្រាស់ភាសាសាមញ្ញ និងងាយស្រួលយល់
- ស្លៀកពាក់ស្អាតបាតអាស្រ័យលើបរិបទ និងវប្បធម៌
- រក្សាព័ត៌មាន/ចម្លើយជាការសម្ងាត់

**អ្វីដែលអ្នកស្រាវជ្រាវមិនគួរធ្វើ៖**

- និយាយច្រើនពេក
- បង្អាក់អ្នកចូលរួមក្នុងការបញ្ចេញគំនិត ឬមតិយោបល់
- ព្យាយាមគ្រប់គ្រងការពិភាក្សា/អ្នកចូលរួម
- លើកឡើងពីបុគ្គលម្នាក់ៗ
- ស្រែកគំហ៊កដាក់អ្នកចូលរួម
- វិនិច្ឆ័យអ្នកចូលរួម
- ប្រើប្រាស់អំណាចជាអ្នកសម្របសម្រួលដើម្បីគាបសង្កត់អ្នកឆ្លើយតប
- ស្លៀកពាក់ឯកសណ្ឋានរបស់មន្ត្រីរដ្ឋាភិបាល/ឯកសណ្ឋានអង្គការ
- បង្ហាញទិន្នន័យ/ព័ត៌មានដល់សាធារណៈដោយគ្មានការព្រមព្រៀងយល់ព្រម

ក្រៅពីជំនាញសម្របសម្រួល និងជំនាញប្រាស្រ័យទាក់ទង ដែលរួមទាំងក្រមសីលធម៌ផងនោះអ្នកស្រាវជ្រាវក៏ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់អំពីការរៀបចំកិច្ចពិភាក្សាក្រុមគោលដៅ (FGDs) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) ដោយសារតែវាអាចប៉ះពាល់ដល់គុណភាពនៃការប្រមូលទិន្នន័យ។ យោងតាមការពន្យល់បកស្រាយពីខាងលើ កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) ត្រូវបង្កើតឡើងដោយមានអ្នកចូលរួមចាប់ពី ៣ – ៥ នាក់ ដូចនេះពួកគេគួរតែអង្គុយជារង្វង់ដើម្បីធ្វើការទំនាក់ទំនងជាមួយគ្នាឱ្យបានយ៉ាងល្អប្រសើរនៅក្នុងក្រុម។ ដំណាលពេលជាមួយគ្នានេះដែរ អ្នកសម្របសម្រួលគួរតែធ្វើការអង្កេតអំពីអន្តរកម្ម និងជំរុញទឹកចិត្តអ្នកឆ្លើយតបណាដែលមិនសូវសកម្មឱ្យចូលរួមបញ្ចេញមតិយោបល់របស់ពួកគេ។ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) គឺជាការសម្ភាសន៍លក្ខណៈបុគ្គល ឬការពិភាក្សាជាគូ ដូចនេះ អ្នកសម្ភាសន៍និងអ្នកឆ្លើយតបគួរតែអង្គុយទល់មុខគ្នានៅកន្លែងដែលសមរម្យដែលពួកគេមានភាពងាយស្រួល និងមិនតានតឹង។



## ជំហានទី ៤៖ ការវិភាគទិន្នន័យ

ទិន្នន័យគុណវិស័យ ដែលបានប្រមូលពីSEGA គឺមានលក្ខណៈអរូបី និងមានលក្ខណៈជាការនិទានជាជាងទិន្នន័យបរិមាណវិស័យ។ អ្នកស្រាវជ្រាវចាំបាច់ត្រូវតែមានការយល់ដឹងច្បាស់លាស់អំពីបញ្ហាបរិបទនិងនិន្នាការ ហើយត្រូវយកចិត្តទុកដាក់ទ្វេដងនៅពេលធ្វើការវិភាគ និងបកស្រាយទិន្នន័យ។

### ❖ អនុជំហានទី ១៖ ការដាក់កូដទិន្នន័យ

ការដាក់កូដ គឺជាវិធីសាស្ត្រមួយក្នុងការសម្គាល់ឬចាត់ថ្នាក់អត្ថបទដើម្បីបង្កើតជាក្របខណ្ឌខ្លឹមសារនៃគំនិត។ ការដាក់កូដ គឺត្រូវបានកត់ត្រាចូលទៅក្នុងតារាងវិភាគដែលអាចបង្កើតនៅក្នុងកម្មវិធី Ms. Word បាន។ អ្នកស្រាវជ្រាវត្រូវតែធ្វើសេចក្តីសន្និដ្ឋានចម្លើយទាំងអស់ដែលបានមកពីអ្នកឆ្លើយតប/ក្រុមនីមួយដោយប្រើប្រាស់បញ្ជីកត់ត្រានៅពេលចុះសម្ភាសន៍ដើម្បីធានាថាការវិភាគទិន្នន័យគឺមិនមានភាពលម្អៀងឡើយ។

| ចំណាត់ថ្នាក់នៃការដាក់កូដ | | | | | |
|---|---|---|---|---|---|
| កំណត់អាកប្បកិរិយានៃការរើសអើង | កំណត់អត្តសញ្ញាណក្រុម/បុគ្គលដែលមិនត្រូវបានគិតគូរ | វិភាគពីដើមចម | វិភាគពីបញ្ហាប្រឈមក្នុងការអនុវត្ត | វិភាគពីលទ្ធផលនិងនិន្នាការអនាគត | កំណត់ដំណោះស្រាយ |
| *ព្យាយាមស្វែងយល់ពីការប្រព្រឹត្តមិនស្មើភាពគ្នា និងបុរេវិនិច្ឆ័យក្នុងបរិបទវិស័យអប់រំ* | *ជូនដំណឹងដល់កុមារដែលងាយរងគ្រោះនៅក្នុងវិស័យអប់រំរបស់ពួកគេ* | *ពិនិត្យកត្តាសំខាន់ៗដែលបង្កភាពមិនមានបរិយាបន្ន និងការរើសអើង* | *ពិនិត្យឧបសគ្គរារាំងសមិទ្ធផលក្នុងស្ថានភាពជាក់ស្តែង* | *ពិនិត្យហានិភ័យ/គ្រោះថ្នាក់នៃតួអង្គចម្បង* | *ស្វែងរកវិធានការ/គំនិតសម្រាប់ការដោះស្រាយបញ្ហានៅក្នុងវិស័យអប់រំ* |

### ❖ អនុជំហានទី ២៖ ការបកស្រាយទិន្នន័យ

ម៉ាទ្រីករបស់ SEGA គឺត្រូវបានបង្កើតឡើងដើម្បីជួយអ្នកស្រាវជ្រាវក្នុងការវិភាគ និងការរៀបចំសរសេររបាយការណ៍ដូចមានបង្ហាញខាងក្រោម៖

| ប្រភេទ | សំណួរ | ចម្លើយ | ការដាក់កូដ | លទ្ធផលរកឃើញ |
|---|---|---|---|---|
| ការផាត់ចេញពីសង្គមនិងយេនឌ័រ | | | | |
| | តើនរណាមិនត្រូវបានគេគិតគូរ ឬបាត់បង់ឱកាសពីប្រព័ន្ធអប់រំក្នុងមូលដ្ឋាន ? | ខ្ញុំគិតថា កុមារពិការ កុមារក្រីក្រ ក្មេងស្រី និងកុមារដែលមកពីគ្រួសារដែលមានអំពើហឹង្សា។ | បុគ្គល និងក្រុមដែលគេមិនគិតគូរ | ការសិក្សានេះរកឃើញថាក្រុមដែលគេមិនគិតគូរក្នុងប្រព័ន្ធអប់រំគឺជាកុមារពិការ ក្មេងស្រី កុមារក្រីក្រ និងកុមារមកពីគ្រួសារដែលមានអំពើហឹង្សាក្នុងគ្រួសារ។ |

ម៉ាទ្រីករបស់ SEGA គឺត្រូវបានបង្កើតឡើងដើម្បីជួយអ្នកស្រាវជ្រាវក្នុងការវិភាគ និងការរៀបចំសរសេររបាយការណ៍ដូចមានបង្ហាញខាងក្រោម៖

## ជំហានទី ៥៖ ការសរសេររបាយការណ៍

ការសរសេររបាយការណ៍គឺជាជំហានចុងក្រោយគេបង្អស់នៅក្នុងដំណើរការសិក្សាពីSEGA។ របាយការណ៍នេះគឺជាសេចក្តីពណ៌នាអំពីការបំពេញកិច្ចការស្រាវជ្រាវនិងលទ្ធផលរកឃើញសំខាន់ៗ ព្រមទាំងអនុសាសន៍ផងដែរ។ របាយការណ៍ត្រូវតែសង្ខេបខ្លី ជាក់លាក់ ច្បាស់លាស់ និងងាយស្រួលអាន និងអនុវត្តតាម។

**ដើម្បីសរសេររបាយការណ៍ឱ្យបានល្អ សូមអានសេចក្តីណែនាំខាងក្រោម៖**

- **សេចក្តីផ្តើម៖** ត្រូវតែសរសេរដោយប្រើគំនិតគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងវិស័យអប់រំ ឬក៏អាចសរសេរទាក់ទងនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ បញ្ហាការផាត់ចេញពីសង្គមនិងយេនឌ័រ។ ជារឿយៗ សេចក្តីផ្តើមគឺសរសេរតែមួយទំព័រប៉ុណ្ណោះ។
- **សេចក្តីសង្ខេប៖** សង្ខេបរបាយការណ៍របស់អ្នក។ ជាធម្មតា សេចក្តីសង្ខេបនេះគឺត្រូវសរសេរបន្ទាប់ពីចំណុចផ្សេងៗទៀតនៅក្នុងរបាយការណ៍គឺត្រូវបានសរសេរចប់សព្វគ្រប់។
- **គោលបំណងនៃការស្រាវជ្រាវ៖** ដកស្រង់ចេញពីលក្ខខណ្ឌយោងរបស់អ្នក។
- **វិធីសាស្ត្រស្រាវជ្រាវ៖** ដកស្រង់ចេញពីសៀវភៅណែនាំ SEGA ឬលក្ខខណ្ឌយោង។
- **វិសាលភាព និងគំរូ៖** ចំណុចទាំងពីរនេះគឺត្រូវបានគូសបង្ហាញនៅក្នុងលក្ខខណ្ឌយោង និងដកស្រង់ចំណុចនេះដាក់ចូលទៅក្នុងរបាយការណ៍របស់អ្នក។
- **លទ្ធផលរកឃើញសំខាន់ៗ៖** ផ្នែកនេះគឺជាចំណុចស្នូលនៃរបាយការណ៍ ដោយសារតែផ្នែកនេះត្រូវរៀបរាប់លម្អិតអំពីលទ្ធផលរកឃើញ និងសំយោគព័ត៌មានទៅជាលទ្ធផលនៃសេចក្តីពណ៌នា។ ជារឿយៗ ផ្នែកនេះមាន 2 ឬ 3 ទំព័រ។
- **អនុសាសន៍៖** ចំណុចនេះត្រូវតែជាគំនិតឆ្លាតវៃ អាចធ្វើទៅបាន អាចសម្រេចបាន ឬអាចរួមបញ្ចូលសេចក្តីណែនាំសម្រាប់ការសិក្សាបន្ថែមដោយផ្អែកលើលទ្ធផលរកឃើញដើម្បីដោះស្រាយបញ្ហាការផាត់ចេញពីសង្គមនិងយេនឌ័រនៅក្នុងប្រព័ន្ធអប់រំ។
- **ឧបសម្ព័ន្ធ៖** ចូរភ្ជាប់លក្ខខណ្ឌយោង និងកម្រងសំណួរដែលអ្នកបានប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវ។

**ទម្រង់គំរូសម្រាប់សរសេររបាយការណ៍ SEGA៖**

**ក្របមុខ**
ចំណងជើងកិច្ចការ
ស្រាវជ្រាវ៖ ....................
ឈ្មោះខេត្ត៖..................
ស្រុក៖..........................
**ឈ្មោះក្រុម៖**
១/..................................
២/..................................
៣/..................................
៤/..................................
៥/..................................
ឆ្នាំ២០១៨ - ២០១៩

**មាតិកា**


សេចក្តីផ្តើម................១
I. សេចក្តីសង្ខេប........២
II. គោលបំណងនៃការស្រាវជ្រាវ..........៣
III. វិធីសាស្ត្រស្រាវជ្រាវ..៤
IV. វិសាលភាព និងគំរូ...៥
V. លទ្ធផលសំខាន់ៗ.....៦
VI. សន្និដ្ឋាន................៧
VII. អនុសាសន៍...........៨


I. សេចក្តីសង្ខេប...........
II. គោលបំណងនៃការស្រាវជ្រាវ
..................................
III. វិធីសាស្ត្រស្រាវជ្រាវ
..................................
IV. វិសាលភាព និងគំរូ
..................................
V. លទ្ធផលសំខាន់ៗ
..................................

VII. សន្និដ្ឋាន
..................................
VIII. អនុសាសន៍
..................................
ឧបសម្ព័ន្ធ I៖ លក្ខខណ្ឌយោង
ឧបសម្ព័ន្ធ II៖ កម្រងសំណួរ
ឧបសម្ព័ន្ធ៖ រចនាសម្ព័ន្ធក្រុម



## ជំហានទី ៦៖ សិក្ខាសាលាផ្សព្វផ្សាយ

សិក្ខាសាលាផ្សព្វផ្សាយស្តីពី SEGA គឺជាជំហានចុងក្រោយគេដ៏សំខាន់បំផុតនៅក្នុងដំណើរការនៃសៀវភៅណែនាំ SEGA ដើម្បីដាក់បញ្ចូលលទ្ធផលរកឃើញសំខាន់ៗទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំនាំរបស់មន្ទីរអប់រំខេត្ត/ការិយាល័យអប់រំស្រុក/សាលា (PoE, DoE, School)។ សិក្ខាសាលានេះគួរតែរៀបចំឡើង បន្ទាប់ពីក្រុម SEGA បានរៀបចំ និងសរសេរបញ្ចប់របាយការណ៍ SEGA ទាំង ៤ (របាយការណ៍ស្រុកចំនួន ៣ និងរបាយការណ៍ខេត្តចំនួន១)។ ដូចនេះ ក្រុមស្រាវជ្រាវត្រូវតែមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំផែនការក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព និងដោយភាពរលូន។

សិក្ខាសាលានេះមានគោលដៅសម្រាប់តែបុគ្គលសំខាន់ៗ ដែលបានចូលរួមនៅក្នុងការបង្កើតផែនការវិស័យអប់រំ និងការគ្រប់គ្រងភាពជាអ្នកដឹកនាំប៉ុណ្ណោះ ដូចនេះអ្នកចូលរួមដែលត្រូវអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលានេះត្រូវតែជាប្រធានមន្ទីរអប់រំខេត្ត ប្រធានការិយាល័យផែនការ សមាជិកក្រុមការងារបច្ចេកទេសនៃមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក និងនាយកសាលាគោលដៅ។ ក្រៅពីមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និងតំណាងរបស់សាលារៀន បុគ្គលសំខាន់ដែលមកពី DGPP គឺត្រូវអញ្ជើញដោយសារតែពួកគេនិងផ្តល់ដំបូន្មានអំពីសង្គតិភាពនៃការធ្វើផែនការរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ របៀបវារៈខាងក្រោមនេះនឹងបង្ហាញពីដំណើរការសិក្ខាសាលា៖

| ប្រធានបទ | ពេលវេលាត្រូវការ | អ្នកសម្របសម្រួល |
|---|---|---|
| ការអញ្ជើញមកដល់ និងចុះឈ្មោះអ្នកចូលរួម | ១៥ នាទី | ពិធីករមកពីក្រុម SEGA |
| ស្វាគមន៍អ្នកចូលរួម និងធ្វើបទបង្ហាញពីកម្មវត្ថុចម្បងនៃកិច្ចប្រជុំ | ១០ នាទី | ពិធីករមកពីក្រុម SEGA |
| ក្រុម SEGA ធ្វើបទបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ SEGA អំពីរបាយការណ៍នីមួយៗរបស់មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក<br>• គោលបំណងនៃការសិក្សា<br>• វិធីសាស្ត្រស្រាវជ្រាវ<br>• វិសាលភាព និងគំរូ<br>• លទ្ធផលរកឃើញសំខាន់ៗ<br>• បញ្ហាប្រឈម<br>• បទពិសោធន៍<br>• សេចក្តីសន្និដ្ឋាន<br>• អនុសាសន៍ | ១២០ នាទី | ពិធីករមកពីក្រុម SEGA |
| សម្រាកអាហារសម្រន់ | ១៥ នាទី | អ្នកចូលរួមទាំងអស់ |
| សំណួរ ចម្លើយ | ១០ នាទី | |
| បែងចែកក្រុមធំទៅជាក្រុមតូចៗតាមថ្នាក់ស្រុក និងថ្នាក់ខេត្ត (នាយកសាលាចូលគ្នាតាមស្រុក) ដើម្បីពិភាក្សាឱ្យបានស៊ីជម្រៅអំពីរបៀបជ្រើសរើស និងផ្តល់អាទិភាពវិធានការ/ដំណោះស្រាយសម្រាប់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ។ | ១ ម៉ោង | ក្រុម SEGA |
| សុន្ទរកថាបញ្ចប់កម្មវិធីដោយប្រធាន ឬតំណាងមន្ទីរអប់រំខេត្ត | ១០ នាទី | ពិធីករមកពីក្រុម SEGA |



# ផ្នែក គ៖
# សេចក្ដីសន្និដ្ឋាន
# SEGA

គឺមិនមែនត្រឹមជាឧបករណ៍ស្រាវជ្រាវដើម្បីបង្កើតឯកសារភស្តុតាងសម្រាប់បង្កើតផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ជាឧបករណ៍ដើម្បីស្វែងរកដើមចមបញ្ហា និងចំណុចខ្វះចន្លោះនៅក្នុងការបង្កើតគោលនយោបាយ និងការអនុវត្តន៍ផងដែរ។ SEGA គឺត្រូវបានបង្កើតឡើងឱ្យកាន់តែមានរបៀបរៀបរយ និងមានភាពជាប្រព័ន្ធជាងមុន ដោយសារតែវាចងភ្ជាប់ការកំណត់បញ្ហាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍ជាមួយគ្នា។ SEGA អាចមានភាពបត់បែនទៅតាមវិសាលភាពនៃការសិក្សា ទំហំគំរូ រយៈពេលដោយអាស្រ័យទៅលើបរិបទ ភូមិសាស្ត្រ ថវិកាដែលមាន និងធនធានមនុស្ស ទើបវាតម្រូវឱ្យមានការរំឭកទ្រឹស្ដីមុននឹងក្រុមស្រាវជ្រាវចាប់ផ្ដើមបង្កើតលក្ខខណ្ឌយោង។

SEGAអាចមើលទៅជាការស្មុគស្មាញសាំញ៉ាំសម្រាប់ក្រុមមនុស្សឬបុគ្គលដែលមិនធ្លាប់បានចូលរួមជាមួយឬធ្វើការស្រាវជ្រាវប៉ុន្តែយើងសង្ឃឹមថាដំណើរការមួយនឹងត្រូវបង្កើតឡើងដើម្បីឱ្យមានភាពងាយស្រួលអនុវត្ត និងងាយស្រួលប្រើប្រាស់ ព្រមទាំងមិនយូរប៉ុន្មានក្រោយមកនឹងបង្កើតបានជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់ជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធ ដែលធានាថាផែនការវិស័យអប់រំគឺផ្អែកទៅលើភស្តុតាង និងមានសមធម៌ពិតប្រាកដ។



# ឧបសម្ព័ន្ធ I ៖ គំរូលក្ខខណ្ឌយោង (ToR)

## ១. សាវតានៃបរិបទ

**សូមសរសេរចំណុចខាងក្រោមឱ្យបានគ្រោះក្បាយៈ**

- *ឈ្មោះទីតាំងមួយ (ឬច្រើន) និងទីតាំងរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា*
- *ព័ត៌មានប្រជាសាស្ត្រមួយចំនួននៃទីតាំង ដូចជាចំនួនប្រជាជន ក្រុមជនជាតិភាគតិច បំណែងចែកអាយុ ចំណាកស្រុក (ប្រសិនបើសំខាន់) និងពិការភាព (ប្រសិនបើមាន)*
- *ជីវភាពរស់នៅចម្បងនៅក្នុងទីតាំង*
- *ព័ត៌មានមួយចំនួនអំពីវិស័យអប់រំដូចជា ចំនួនសាលារៀនតាមអនុវិស័យ ចំនួនមជ្ឈមណ្ឌលយុវជន (ប្រសិនបើមាន) ស្ថិតិសំខាន់ៗដូចជាការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សាតាមអនុវិស័យ និងបែងចែកដាច់ដោយឡែកតាមភេទ*
- *បញ្ហាប្រឈមសំខាន់ៗជាងគេចំនួន ៣ សម្រាប់ការផ្តល់នូវការអប់រំប្រកបដោយគុណភាព និងសមធម៌នៅក្នុងទីតាំង*
- *អាទិភាពសំខាន់ជាងគេបំផុតចំនួន ៣ នៅក្នុង P-ESP និង/ឬ P-AOP និង/ឬ D-AOP បច្ចុប្បន្ន។*

## ២. ការកំណត់បញ្ហា

កាលពីឆ្នាំមុន/ប៉ុន្មានឆ្នាំមុន វិស័យអប់រំនៅក្នុង [ឈ្មោះទីតាំង] មានការរីកចម្រើនតាមវិធីសាស្ត្រដូចជា៖ *[សរសេរពីការរីកចម្រើន]។* ក៏ប៉ុន្តែ តាមរយៈស្ថិតិខាងលើ កុមារ និងយុវជនមួយចំនួនគឺមិនបានចុះឈ្មោះចូលរៀន ឬរៀនមិនបានចប់ចុងចប់ដើមឡើយ។ [សរសេរបញ្ហាវិស័យអប់រំជាក់លាក់សម្រាប់ទីតាំងនោះ]

## ៣. គោលបំណងនៃការសិក្សា

គោលបំណងរួមរបស់ SEGA គឺដើម្បីស្វែងយល់ និងរកឱ្យឃើញនូវដើមចមនៃមូលហេតុធ្វើឱ្យកុមារ និងយុវជន *[ឈ្មោះទីតាំង]* រៀនមិនបានល្អ និងមិនបានជោគជ័យក្នុងការរៀនសូត្រ និងដើម្បីវាយតម្លៃអំពីជំនឿរបស់ពួកគេ និងឪពុកម្តាយ/អ្នកថែទាំរបស់ពួកក្នុងការផ្លាស់ប្តូរ/អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពបំផុត។

## ៤. វិធីសាស្ត្រស្រាវជ្រាវ

SEGA គឺជាដំណើរការស្រាវជ្រាវបែបគុណភាព។ ការត្រួតពិនិត្យឯកសារ ការពិភាក្សាក្រុមគោលដៅ (FGDs) និងការសម្ភាសន៍បុគ្គលព័ត៌មានសំខាន់ៗ(KIIs) គឺជាវិធីសាស្ត្រស្រាវជ្រាវដែលត្រូវបានប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យដើម្បីធ្វើការវិភាគអំពីចំណេះដឹង ឥរិយាបទ ការអនុវត្ត និងគោលគំនិតនៃអ្នកប្រើប្រាស់សេវាកម្ម និងអ្នកផ្តល់សេវាកម្ម។ FGDs គឺត្រូវបានអនុវត្តជាមួយអ្នកប្រើប្រាស់សេវាកម្មដូចជាឪពុកម្តាយ យុវជន កុមារដែលមិនបានចូលរៀន កុមារពិការ អ្នកឆ្លើយតបជាជនជាតិដើមភាគតិច និងជាជនម្ចាស់ស្រុក ហើយការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) គឺត្រូវបានប្រើប្រាស់ជាមួយអ្នកផ្តល់សេវាកម្មមានដូចជាគ្រូបង្រៀន និងនាយកសាលាដោយការបែងចែកទៅជាភេទ អាយុ និងយេនឌ័រខុសៗគ្នា។

## ៥. វិសាលភាព និងគំរូ

ការសិក្សាពី SEGA នឹងធ្វើឡើងនៅខេត្ត _____ និងស្រុក _____ ។ _____ សាលាគំរូ និង _____ អ្នកឆ្លើយតប /FGDs នឹងត្រូវជ្រើសរើសតាមការចាប់ដោយចៃដន្យ។ ចំនួនអ្នកចូលរួមដែលបានប៉ាន់ស្មានគឺ _____ រួមមាន ៥០% ជាស្ត្រី និងក្មេងស្រី។

## ៦. ក្រុមស្រាវជ្រាវ

ក្រុម SEGA នឹងបង្កើតឡើងពីមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និងនាយកសាលា។ ក្រុមស្រាវជ្រាវមានសមាជិក ៧ នាក់រួមមាន _____ ជាស្ត្រី ហើយមាន មន្ទីរអប់រំខេត្ត ម្នាក់ ការិយាល័យអប់រំស្រុក ៣ នាក់ និងនាយកសាលា ៣ នាក់។

## ៧. រយៈពេល

ការស្រាវជ្រាវពី SEGA នឹងចាប់ផ្តើមនៅ _____ ដល់ _____។

## ៨. លទ្ធផលរំពឹងទុក

ជាលទ្ធផល ដើមចមនៃការផាត់ចេញពីសង្គមនិងយេនឌ័រនៅក្នុងវិស័យអប់រំនៅថ្នាក់ក្រោមជាតិនឹងត្រូវបានរកឃើញជាមួយនឹងសកម្មភាព/អន្តរាគមន៍សមស្របដែលបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ វិស័យអប់រំ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ។

# ឧបសម្ព័ន្ធ II៖ គំរូកម្រងសំណួរ

## ការពិភាក្សាក្រុមគោលដៅ (FGD)

**ក. សេចក្តីផ្តើម**

អារុណ/ទិវាសួស្តី! ជាបឋម ខ្ញុំសូមណែនាំខ្លួនមុននឹងយើងចាប់ផ្តើមកិច្ចពិភាក្សាទៅលើប្រធានបទរបស់យើងនៅថ្ងៃនេះ។ ខ្ញុំឈ្មោះ ________ ហើយមិត្តរួមការងាររបស់ខ្ញុំឈ្មោះ ________។ ពួកយើងទាំងពីរនាក់មកពី ________។

សូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នកក្នុងការចូលរួមក្នុងកិច្ចពិភាក្សារបស់យើងនៅថ្ងៃនេះក៏ដូចជាសូមថ្លែងអំណរគុណចំពោះការចែករំលែកគំនិត មតិយោបល់ បទពិសោធន៍ និងការយល់ដឹងរបស់លោកអ្នកទៅលើប្រធានដែលយើងលើកយកមកពិភាក្សានៅថ្ងៃនេះ។ បច្ចុប្បន្នយើងកំពុងធ្វើការអង្កេតទៅលើការផាត់ចេញពីសង្គម និងវិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំថ្នាក់ក្រោមជាតិ ដែលមានគោលដៅស៊ើបអង្កេត និងសង្កេតអំពីចំណេះដឹង គោលគំនិត ការអនុវត្ត និងស្វែងរកមតិត្រឡប់និងអនុសាសន៍ពីឪពុកម្តាយ សិស្ស គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលា និងភាគីពាក់ព័ន្ធក្នុងការបង្កើតឯកសារផ្អែកលើភស្តុតាងដើម្បីជូនដំណឹងដល់អ្នកបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត និងបុគ្គលដែលទទួលបន្ទុកដើម្បីពង្រឹងគុណភាពវិស័យអប់រំ។

ដូចនេះ រាល់ព័ត៌មាន ឬចម្លើយដែលបានផ្តល់ជូននៅក្នុងកិច្ចពិភាក្សានេះនិងរក្សាទុកជាអនាមិកដោយមិនបញ្ចេញអត្តសញ្ញាណ។ មានន័យថា យើងនឹងមិនចែករំលែកទិន្នន័យនោះទេ ហើយទិន្នន័យទាំងនេះនឹងមិនភ្ជាប់កាតព្វកិច្ចចំពោះបុគ្គលឬក្រុមណាមួយឡើយ។ កិច្ចពិភាក្សារបស់យើងប្រហែលជាចំណាយពេលប្រហែល១ម៉ោង។ ដូច្នេះខ្ញុំសូមស្នើសុំអ្នកចូលរួមទាំងអស់ មេត្តាអត់ធ្មត់។ ប្រសិនបើមានសំណួរ ឬស្នើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់ សូមប្រាប់ដល់យើងខ្ញុំមុននឹងសួរសំណួរ។

**មុននឹងខ្ញុំចាប់ផ្តើមសួរសំណួរ ខ្ញុំសូមផ្តល់និយមន័យមួយចំនួនដោយសង្ខេបថា៖**

- **ការផាត់ចេញពីសង្គម** *សំដៅដល់មនុស្ស ឬក្រុមដែលត្រូវបានគេបដិសេធជាលក្ខណៈប្រព័ន្ធចំពោះសិទ្ធិ ធនធាន សេវាកម្ម ឱកាស សេចក្តីថ្លៃថ្នូរ និងសមត្ថភាពក្នុងការចូលរួមក្នុងជីវិតសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។*
- **សមភាពយេនឌ័រ** *គឺជាស្ថានភាពមួយដែលស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស និងបុគ្គលមិនត្រូវកំណត់ថាជាប្រុស ឬក៏ជាស្រី ទទួលបាននូវសិទ្ធិ ធនធាន ឱកាស និងការការពារដូចគ្នា។*

*សូមចំណាយពេលពីរបីនាទីដើម្បីគិតអំពីសំណួរទាំងនេះ ជជែកគ្នាខ្លីៗដើម្បីធានាថាអ្នកយល់ ហើយសួរសំណួរនៅពេលដែលអ្នកមិនច្បាស់នៅពេលដែលយើងនឹងសួរអ្នកអំពីសំណួរទាំងនេះ។*

**ខ. ការផាត់ចេញពីសង្គមនិងយេនឌ័រ**

១. តើកុមារណាខ្លះដែលត្រូវបាត់បង់ឱកាស ឬមិនត្រូវបានគេគិតគូរនៅក្នុងប្រព័ន្ធអប់រំ?
២. ហេតុអ្វីបានជាកុមារខាងលើ (កុមារនៅក្នុងសំណួរទី១) ត្រូវបានគេមិនគិតគូរនៅក្នុងវិស័យអប់រំក្នុងមូលដ្ឋាន?ដោយរបៀបណា?
៣. តើអ្នកគិតថាសាលាគឺជាកន្លែងមានមេត្រីភាពសម្រាប់កុមារពិការដែរឬទេ? ប្រសិនបើមែន/មិនមែន ហេតុអ្វី?
៤. តើការដែលមានកម្មវិធីសិក្សាពិសេសសម្រាប់កុមារពិការ និងកុមារមកពីក្រុមជនជាតិភាគតិច (អ៊ីស្លាម វៀតណាម ឡាវ....) និងសហគមន៍ជនជាតិដើមភាគតិចនៅសាលាក្នុងមូលដ្ឋានពិតជាចាំបាច់មែនដែរឬទេ? ប្រសិនបើមែន/មិនមែន ហេតុអ្វី?
៥. តើនរណាដែលប្រឈមមុខនឹងការបោះបង់ការសិក្សាខ្ពស់ជាងគេ? តើមានកត្តាបញ្ហាសំខាន់ៗអ្វីខ្លះ?
៦. តើអ្នកយល់ស្របឬទេដែលថាយេនឌ័រគឺជាកត្តាសំខាន់មួយនៃការបោះបង់ចោលការសិក្សា? ប្រសិនបើយល់ស្រប/មិនយល់ស្រប សូមរៀបរាប់ឱ្យបានក្បោះក្បាយ។
៧. រវាងក្មេងប្រុសនិងក្មេងស្រី តើអ្នកផ្តល់អាទិភាពដល់នរណាសម្រាប់ថ្នាក់ឧត្តមសិក្សា? ហេតុអ្វី?
៨. តើវាពិតជាសំខាន់មែនដែរឬទេក្នុងការផ្តាច់បង្គន់ក្មេងប្រុស និងក្មេងស្រីដាច់ដោយឡែកពីគ្នានៅសាលារៀនក្នុងមូលដ្ឋាន? ហេតុអ្វី?
៩. តើមានផលវិបាកអ្វីខ្លះប្រសិនបើបញ្ហាទាំងនេះនៅតែកើតមានឡើង? (ចំពោះបុគ្គល គ្រួសារ និងសហគមន៍)
១០. តើត្រូវធ្វើអ្វីដើម្បីគាំទ្រកុមារងាយរងគ្រោះ ឬកុមារដែលមិនត្រូវបានគេគិតគូរក្នុងការសម្រេចឱ្យបាននូវសមភាពវិស័យអប់រំក្នុងមូលដ្ឋាន?

**គ. សេចក្តីណែនាំ /អនុសាសន៍**

១១. ជាចុងក្រោយ តើអ្នកមានសេចក្តីណែនាំ ឬអនុសាសន៍សម្រាប់សាលា ឬអ្នកផ្តល់សេវាកម្មអប់រំក្នុងការពង្រឹងវិស័យអប់រំដើម្បីឱ្យគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្ន?

# ការសម្ភាសន៍ជាមួយបុគ្គលសំខាន់ (KII)

**ក. សេចក្តីផ្តើម**

ជំរាបសួរ! អារុណ/ទិវាសួស្តី។ ជាបឋម ខ្ញុំសូមណែនាំខ្លួនមុននឹងយើងចាប់ផ្តើមកិច្ចពិភាក្សាទៅលើប្រធានបទរបស់យើងនៅថ្ងៃនេះ។ ខ្ញុំឈ្មោះ ________ ហើយមិត្តរួមការងាររបស់ខ្ញុំឈ្មោះ ________។ ពួកយើងទាំងពីរនាក់មកពី ________។ គោលបំណងនៃការសម្ភាស ________។

សូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់អ្នកដើម្បីចូលរួមក្នុងកិច្ចពិភាក្សារបស់យើងនៅថ្ងៃនេះក៏ដូចជាសូមថ្លែងអំណរគុណចំពោះការចែករំលែកគំនិត មតិយោបល់ បទពិសោធន៍ និងការយល់ដឹងរបស់លោកអ្នកទៅលើប្រធានដែលយើងលើកយកមកពិភាក្សានៅថ្ងៃនេះ។ បច្ចុប្បន្ន យើងកំពុងធ្វើការអង្កេតលើអបរិយាបន្នសង្គម និងវិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំថ្នាក់ក្រោមជាតិ ដែលមានគោលដៅស៊ើបអង្កេត និងអង្កេតអំពីចំណេះដឹង គោលគំនិត ការអនុវត្ត និងស្វែងរកមតិត្រឡប់ និងអនុសាសន៍ពីឪពុកម្តាយ សិស្ស គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលា និងភាគីពាក់ព័ន្ធក្នុងការបង្កើតឯកសារផ្អែកលើភស្តុតាងដើម្បីជូនដំណឹងដល់អ្នកបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត និងបុគ្គលដែលទទួលបន្ទុកដើម្បីពង្រឹងគុណភាពវិស័យអប់រំ។

ដូចនេះ រាល់ព័ត៌មាន ឬចម្លើយដែលបានផ្តល់ជូននៅក្នុងកិច្ចពិភាក្សានេះនឹងរក្សាទុកជាការសម្ងាត់ជូន មានន័យថា យើងនឹងមិនចែករំលែកទិន្នន័យនោះទេ ហើយទិន្នន័យទាំងនេះនឹងមិនភ្ជាប់កាតព្វកិច្ចចំពោះបុគ្គល ឬក្រុមណាមួយឡើយ។

កិច្ចពិភាក្សារបស់យើងអាចចំណាយពេលប្រហែល 1 ម៉ោង។ ដូច្នេះខ្ញុំសូមណែនាំឱ្យអ្នកដែលចូលរួមទាំងអស់មេត្តាអត់ធ្មត់។ ប្រសិនបើអ្នកមានសំណួរ ឬស្នើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់ សូមផ្តល់ដំណឹងដល់យើងខ្ញុំមុននឹងយើងចាប់ផ្តើមសួរសំណួរ។

**មុននឹងខ្ញុំចាប់ផ្តើមសួរសំណួរ ខ្ញុំសូមផ្តល់និយមន័យមួយចំនួនដោយសង្ខេបថា៖**

- **ការផាត់ចេញពីសង្គម** *សម្តៅដល់មនុស្ស ឬក្រុមដែលត្រូវបានគេបដិសេធជាលក្ខណៈប្រព័ន្ធចំពោះសិទ្ធិ ធនធាន សេវាកម្ម ឱកាស សេចក្តីថ្លៃថ្នូរ និងសមត្ថភាពក្នុងការចូលរួមក្នុងជីវិតសង្គម សេដ្ឋកិច្ច វប្បធម៌ និងឆាកនយោបាយ។*
- **សមភាពយេនឌ័រ** *គឺជាស្ថានភាពមួយដែលស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស និងបុគ្គលមិនត្រូវកំណត់ថាជាប្រុស ឬក៏ជាស្រី ទទួលបាននូវសិទ្ធិ ធនធាន ឱកាស និងការការពារដូចគ្នា។*

*សូមចំណាយពេលពីរបីនាទីដើម្បីគិតអំពីសំណួរទាំងនេះ ជជែកគ្នាខ្លីៗដើម្បីធានាថាអ្នកយល់ ហើយសួរសំណួរនៅពេលដែលអ្នកមិនច្បាស់នៅពេលដែលយើងសួរអ្នកអំពីសំណួរទាំងនេះ។*

**ខ. ការផាត់ចេញពីសង្គមនិងយេនឌ័រ**

១. តើកុមារណាខ្លះដែលត្រូវបាត់បង់ឱកាស ឬមិនត្រូវបានគេគិតគូរនៅក្នុងប្រព័ន្ធអប់រំ? ហេតុអ្វី? ដោយរបៀបណា?
២. តើអ្នកគិតថាសាលាគឺជាកន្លែងមានមេត្រីភាពសម្រាប់កុមារពិការដែរឬទេ? ប្រសិនបើមែន/មិនមែន ហេតុអ្វី?(សូមឱ្យឧទាហរណ៍)
៣. តើការដែលមានកម្មវិធីសិក្សាពិសេសសម្រាប់កុមារពិការ និងកុមារមកពីជនជាតិដើមភាគតិច (អ៊ីស្លាម វៀតណាម ឡាវ....) និងសហគមន៍ម្ចាស់ស្រុកនៅសាលាក្នុងមូលដ្ឋានពិតជាចាំបាច់មែនដែរឬទេ? ប្រសិនបើមែន/មិនមែន ហេតុអ្វី? ដោយរបៀបណា?
៤. តើនរណាដែលជាតួអង្គសំខាន់ក្នុងការធានាកម្មវិធីសិក្សាពិសេសនៅសាលារៀនក្នុងមូលដ្ឋាន?
៥. តើនរណាដែលប្រឈមមុខនឹងការបោះបង់ការសិក្សាខ្ពស់ជាងគេ? តើមានកត្តាបញ្ហាសំខាន់ៗអ្វីខ្លះចំពោះបញ្ហានេះ?
៦. តើអ្នកយល់ស្របឬទេដែលថាយេនឌ័រគឺជាកត្តាសំខាន់មួយនៃការបោះបង់ចោលការសិក្សា? ប្រសិនបើយល់ស្រប/មិនយល់ស្រប សូមរៀបរាប់ឱ្យបានក្បោះក្បាយ។
៧. រវាងក្មេងប្រុស និងក្មេងស្រី តើអ្នកផ្តល់អាទិភាពដល់នរណាសម្រាប់ថ្នាក់ឧត្តមសិក្សា? ហេតុអ្វី
៨. ឪពុកម្តាយកំពុងតែពិភាក្សាគ្នាអំពីការផ្តល់អាទិភាពរៀនសូត្រដល់កូនៗដោយពួកគាត់ពេញចិត្តឱ្យកូនប្រុសបានចូលរៀនថ្នាក់ឧត្តមសិក្សាជាង។ អ្នកបានឮការពិភាក្សានេះដោយចៃដន្យ ហើយតើអ្នកគួរធ្វើអ្វី?
៩. តាមរយៈបទពិសោធន៍របស់អ្នក តើគ្រូប្រព្រឹត្តចំពោះសិស្សខុសគ្នាតាមយេនឌ័រដែរឬទេ? (ឧទាហរណ៍ ការកំណត់តួនាទី និងទំនួលខុសត្រូវ)
១០. តើមានផលវិបាកអ្វីខ្លះប្រសិនបើបញ្ហាទាំងនេះនៅតែកើតមានឡើង? (ចំពោះបុគ្គល គ្រួសារ និងសហគមន៍)
១១. តើត្រូវធ្វើអ្វីដើម្បីគាំទ្រកុមារងាយរងគ្រោះ ឬកុមារដែលមិនត្រូវបានគេគិតគូរក្នុងការសម្រេចឱ្យបាននូវសមភាពវិស័យអប់រំក្នុងមូលដ្ឋាន?

**គ. សេចក្តីណែនាំ /អនុសាសន៍**

១២. ជាចុងក្រោយ តើអ្នកមានសេចក្តីណែនាំ ឬអនុសាសន៍សម្រាប់សាលា ឬអ្នកផ្តល់សេវាកម្មអប់រំក្នុងការពង្រឹងវិស័យអប់រំដើម្បីឱ្យគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្នដែរឬទេ?

#17, Street 234. Sangkat Phsar Doeum Kor,
Khan Tuol Kork, Phnom Penh, Cambodia

Tel: 023 882 768

www.vsointernation.org